# ក្រុមមេធាវីការពារក្តីរបស់លោក អោ អាន
# AO An Defence Team

ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៨

**សូមគោរពជូន៖** លោកចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង
លោកចៅក្រម យ៉ា សុខន
លោកចៅក្រម យូ ឧត្តរា
លោកស្រីចៅក្រម Claudia FENZ
លោកចៅក្រម Martin KAROPKIN

**ចម្លងជូន៖** លោកស្រី ជា លាង សហព្រះរាជអាជ្ញាជាតិ
លោកស្រី Brenda HOLLIS សហព្រះរាជអាជ្ញាអន្តរជាតិ

***កម្មវត្ថុ៖ សំណើសុំការបញ្ជាក់ថាអង្គជំនុំជម្រះសាលាដំបូងមិនបានទទួលដោយស្របច្បាប់នូវសំណុំរឿង ០០៤/២ និង សំណើសុំពេលវេលាបន្ថែម និង ការណែនាំលើការដាក់ អញ្ញត្រកម្ម អនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង***

**លោកប្រធាន និល ណុន និង លោក លោកស្រីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងជាទីគោរព**

សហមេធាវីការពារក្តីរបស់លោក អោ អាន (បន្ទាប់ពីនេះហៅកាត់ថា "*សហមេធាវីការពារក្តី*") សូមគោរពដាក់សំណើជូនដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងមិនបានទទួលសំណុំរឿង ០០៤/២ នោះទេ ដោយហេតុផលថា ការបញ្ជូនសំណុំរឿង ០០៤/២ ដោយចៅក្រមភាគតិចនៃអង្គបុរេជំនុំជម្រះ ធ្វើឡើងដោយខុសច្បាប់។

នៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៨ នៅក្នុង*សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ("*សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍*") ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះចំនួនពីរ(2)រូបបានបង្គាប់ឱ្យក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះបញ្ជូនសំណុំរឿង ០០៤/២ ទៅអង្គជំនុំជម្រះសាលាដំបូង និងបានលើកឡើងថាអង្គបុរេអាចប្តឹងទៅអង្គជំនុំជម្រះសាលាដំបូងបាន ដោយឈរលើមូលដ្ឋាន*ដីកាដំណោះស្រាយបញ្ជូនរឿងទៅជម្រះ* អនុលោមតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង។[1]

[1] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះ*

ដោយការអនុវត្តជាឯកតោភាគី ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ កំពុងព្យាយាមអនុវត្តគេចចេញពីច្បាប់របស់ អ.វ.ត.ក និងសហការីជាតិរបស់ខ្លួន(ចៅក្រមជាតិ) ដើម្បីបន្តនីតិវិធីដោយខុសច្បាប់លើបណ្តឹងប្រឆាំងនឹង អោ អាន។[2] នៅក្នុង*សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍* អង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆន្ទថា ការចេញដីកាដំណោះស្រាយពីរដាច់ពីគ្នាបានរំលោភបំពានលើក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក និង "បង្កើតជាស្ថានភាពគតិយុត្តិដែលមិនធ្លាប់មាន"។[3] អង្គបុរេជំនុំជម្រះពុំបានទទួលបាននូវសម្លេងគាំទ្រភាគច្រើនលើសលប់ក្នុងការចេញនូវសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយពីរនោះទេ *ជាក់ស្តែងដូចជា* ថាតើ អ.វ.ត.ក មានយុត្តាធិការក្នុងការចោទប្រកាន់ ឬលើកលែងការចោទប្រកាន់ចំពោះលោក អោ អាន លើបទឧក្រិដ្ឋដែលបានចោទប្តឹងឬក៏យ៉ាងណានោះទេ។ ក្នុងនោះផងដែរ ក៏គ្មានវិធានឬយន្តការតាមបទបញ្ញត្តិច្បាប់ណាមួយដើម្បីដោះស្រាយទៅលើស្ថានភាពគតិយុត្តដែលមិនធ្លាប់មាននេះដែរ ហេតុដូច្នេះសំណុំរឿងប្រឆាំងនឹងលោក អោ អាន ត្រូវតែលើកលែងការចោទប្រកាន់ ដោយអនុលោមតាមគោលការណ៍សន្មត់ជាមុនថាគ្មានទោស និង គោលការណ៍*វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងភាពច្បាស់លាស់នៃច្បាប់ (legal certainty) ដូចដែលបានកំណត់ក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ទោះបីជាចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានចូលរួមក្នុងការសម្រេចជាឯកច្ឆន្ទ ពាក់ព័ន្ធនឹងការចេញដោយខុសច្បាប់នូវដីកាដំណោះស្រាយពីរ ពួកគាត់បែជាចេញនូវការពិចារណាដាច់ដោយឡែកទៅលើយុត្តាធិការបុគ្គល និងបញ្ជាក់ពីបំណងក្នុងការបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូងដោយផ្អែកលើ*ដីកាដំណោះស្រាយបញ្ជូនរឿងទៅជម្រះ*។ ចៅក្រមអន្តរជាតិទាំងពីរ មិនអើពើទាំងស្រុងទៅលើការពិតដែលថាអង្គបុរេជំនុំជម្រះពុំទទួលបានសម្លេងភាគច្រើនក្នុងការច្រានចោល *ដីកាដំណោះស្រាយបញ្ជូនរឿងទៅជម្រះ* ឬក៏ *ដីកាដំណោះស្រាយលើកលែងការប្រកាន់* ឬ បញ្ជាក់អំពីយុត្តាធិការបុគ្គលនោះទេ ហើយ

---

*ស្រាយ* (*"សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍"*), ឯកសារលេខ D359/24 និង D360/33 ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៩, កថាខណ្ឌ ៦៨៧, ៦៩៤។

[2] *សូមមើល* សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាជាតិ "សហព្រះរាជអាជ្ញាជាតិ កត់សម្គាល់ឃើញថា ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺខុសច្បាប់ ស្របតាមអំណាចសាលដីការបស់អង្គបុរេជំនុំជម្រះ ដែលបាន **ប្រកាស** ថា "**ការចេញដីកាដំណើស្រាយពីរ ដែលផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់ ហើយរំលោភបំពានទៅលើក្របខណ្ឌគតិយុត្តរបស់អ.វ.ត.ក**"។ នៅក្នុងសេចក្តីសម្រេចរបស់ចៅក្រមនៃអង្គបុរេជំនុំជម្រះជាឯកច្ឆ័ន្ទបានប្រកាសថាជនត្រូវចោទ អោ អាន សហព្រះរាជអាជ្ញាជាតិបានសម្គាល់ថាអង្គបុរេជំនុំជម្រះពុំបានបង្គាប់ឲ្យក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះបញ្ជូនសេចក្តីសម្រេច ឬសំណុំរឿងនេះ ដែលមាននៅក្នុងសេចក្តីសម្រេចកន្លងមកពីមុនៗមក។ (https://eccc.gov.kh/sites/default/files/media/INTERNATIONAL%20AND%20NATIONAL%20OCP%27S%20STATEMENT%2024%20DEC%202019.pdf)

[3] *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍,* កថាខណ្ឌ ៨៩។

ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបែរជាទៅបង្គាប់ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះបញ្ជូនសំណុំរឿងលេខ ០០៤/២ ទៅអង្គជំនុំជម្រះសាលាដំបូង ដោយជឿជាក់ថាពួកគាត់មានអំណាចក្នុងការធ្វើដូច្នេះបាន ដោយអនុលោមតាមវិធាន៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង។ ទោះយ៉ាងណាក្តី ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះផ្អែកលើវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង គឺមិនត្រឹមត្រូវទេ ដោយសារវិធាននេះគឺពិចារណាទៅលើតែស្ថានភាពដែលមានដីកាដំណោះស្រាយមួយតែប៉ុណ្ណោះ។ ស្ថានភាពនៅពេលនេះគឺថា យើងមានដីកាដំណោះស្រាយចំនួនពីរ(២)ក្នុងរឿងក្តីតែមួយ ដែលមួយក្នុងចំណោមនោះជាដីកាដំណោះស្រាយលើកលែងការចោទប្រកាន់លើ លោក អោ អាន និងទទួលបានការគាំទ្រពីចៅក្រមភាគច្រើន។ វាគួរតែមានការលើកឡើងផងដែរនូវវិធាន ៧៩(១) ស្តីពីការបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូងដោយអង្គបុរេជំនុំជម្រះ។ ជាថ្មីម្តងទៀត អង្គបុរេជំនុំជម្រះ ***ពុំ***បានប្តឹងទៅអង្គជំនុំជម្រះសាលាដំបូងនោះទេ។

ចៅក្រមភាគតិច(២រូប)នៃអង្គបុរេជំនុំជម្រះ មិនអាចមើលរំលងសេចក្តីសម្រេចដោយចៅក្រមភាគច្រើន(៣រូប)នៃអង្គបុរេជំនុំជម្រះ ដែលចៅក្រមភាគច្រើនបានធ្វើមោឃភាពលើ*ដីកាដំណោះស្រាយបញ្ជូនរឿងទៅជម្រះ* និងរកឃើញថាតុលាការខ្វះយុត្តាធិការក្នុងការចោទប្រកាន់ទៅលើលោក អោ អាន នោះទេ។[4] ការបញ្ជូនសំណុំរឿងរបស់លោក អោ អាន ទៅជំនុំជម្រះក្នុងខណៈដែលចៅក្រមភាគច្រើនរកឃើញថាតុលាការនេះខ្វះយុត្តាធិការ គឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់ លោក អោ អាន ក្នុងការទទួលបានការសន្មត់ជាមុនថាគ្មានទោស។ ការសម្រេចបែបនេះមិនអាចធ្វើឡើងដោយចៅក្រមអន្តរជាតិតែពីរ(២)រូបតែឯកឯងនោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូង ត្រូវបានស្នើសុំឲ្យបញ្ជាក់ថា ខ្លួនមិនបានទទួលដោយស្របច្បាប់នូវសំណុំរឿងលេខ ០០៤/២ នោះទេ។ ម្យ៉ាងទៀត យើងខ្ញុំសូមស្នើសុំថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងនឹងមិនទទួលយកនូវសំណុំរឿងដែល ***មិនបាន*** បញ្ជូនដោយអង្គបុរេជំនុំជម្រះ ប៉ុន្តែបានបញ្ជូនដោយចៅក្រមភាគតិច(ចៅក្រមអន្តរជាតិពីររូប)ទាំងដែលចៅក្រមទាំងពីរគ្មានអំណាចណាមួយដែលមានចែងក្នុងច្បាប់ឲ្យធ្វើដូច្នោះទៀត ហេតុដូច្នេះនៅក្នុងសេណារីយ៉ូដូចនេះ អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធមិនធ្វើសកម្មភាពលើសំណុំរឿងនេះតែម្តង។ និយាយដូច្នេះមានន័យថា អង្គជំនុំជម្រះ ក៏អាចមិនអើពើនឹងលិខិតមួយនេះដែរ (ដោយហេតុថាអង្គជំនុំជម្រះសាលាដំបូង មិនបានទទួលយកសំណុំរឿងនេះពីអង្គបុរេទេ)។

ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងនឹងគិតថាខ្លួនបានទទួលយកសំណុំរឿងនេះ សហមេធាវីការពារក្តីសូមស្នើសុំឲ្យមានការណែនាំអំពីជំហានបន្ទាប់។ ដោយសារតែគ្មានសេចក្តីសម្រេចជាក់លាក់ណាមួយដោយសម្លេងភាគច្រើនទៅលើដីកាដំណោះស្រាយណាមួយ វាមិនមានភាពមិនច្បាស់លាស់អំពីពេល

---

[4] *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍*, កថាខណ្ឌ ៣០២។

វេលាកំណត់សម្រាប់ការធ្វើអញ្ញត្រកម្ម។ ស្របតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង ភាគីទាំងអស់ "មានរយៈពេល ៣០ ថ្ងៃបន្ទាប់ពីដីកាដំណោះស្រាយចូលជាស្ថាពរ" ដើម្បីដាក់ការធ្វើអញ្ញត្រកម្ម។

សហមេធាវីការពារក្តី សូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថាខ្លួនមានបំណងធ្វើអញ្ញត្រកម្មលើចំណុចជាច្រើន ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងគិតថាខ្លួននឹងទទួលយកសំណុំរឿងនេះ។ ផ្នែកមួយ(មិនមែនទាំងស្រុង)នៃការធ្វើអញ្ញត្រកម្ម នឹងផ្តោតទៅលើយុត្តិធិការបុគ្គលរបស់ អ.វ.ត.ក។ ដើម្បីប្រយោជន៍នៃភាពយុត្តិធម៌ វាគួរតែមានការដាក់អញ្ញត្រកម្មទាក់ទងទៅនឹងយុត្តាធិការបុគ្គលក្នុងពេលវេលាកំណត់មួយ និងមានការអនុញ្ញាតឲ្យសហមេធាវីការពារក្តី បានដាក់ម្តងទៀតនូវអញ្ញត្រកម្មទាក់ទងទៅនឹងបញ្ហាផ្សេងដាច់ដោយឡែក ក្នុងពេលវេលាដោយឡែក ប្រសិនបើ និងនៅពេលដែលយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក នៅក្នុងសំណុំរឿងបច្ចុប្បន្ននេះ នឹងត្រូវបានបញ្ជាក់។ សហមេធាវីការពារក្តី សូមស្នើសុំពេលវេលាគ្រប់គ្រាន់ និងសមស្រប ចំនួន៦០ថ្ងៃ ក្នុងការដាក់សារណាអំពីការធ្វើអញ្ញត្រកម្មទាក់ទងទៅនឹងយុត្តាធិការបុគ្គល។ សហមេធាវីការពារក្តីសូមរក្សាសិទ្ធិក្នុងការដាក់នូវអញ្ញត្រកម្មផ្សេងៗទៀត ក្នុងពេលវេលាសមស្របមួយ ប្រសិនបើមានការបញ្ជាក់ពីយុត្តាធិការបុគ្គលដោយសម្លេងភាគច្រើនពីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង។

សរុបមក សហមេធាវីការពារក្តីសូមស្នើសុំដោយគោរពឲ្យ៖

ក. អង្គជំនុំជម្រះសាលាដំបូង បញ្ជាក់ថាខ្លួនមិនបានទទួលយកសំណុំរឿងរបស់លោក អោ អាន ដោយហេតុថា សំណុំរឿងនេះមិនត្រូវបានបញ្ជូនដោយអង្គបុរេជំនុំជម្រះទេ។

ខ. ជម្រើសយ៉ាងម៉ឺងម៉ាត់ ផ្តល់ការណែនាំដល់សហមេធាវីការពារក្តី ក្នុងការដាក់អញ្ញត្រកម្មដោយយោងតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង ដោយផ្តោតទៅលើអញ្ញត្រកម្មដំបូងគឺលើបញ្ហាយុត្តាធិការបុគ្គល (ដោយមិនមានបុរេវិនិច្ឆ័យចំពោះសិទ្ធិរបស់សហមេធាវីការពារក្តីក្នុងការដាក់នូវអញ្ញត្រកម្មផ្សេងទៀត) និងផ្តល់ឲ្យនូវពេលវេលាសមស្របមួយសម្រាប់សហមេធាវីការពាក្តី (យ៉ាងហោច ៦០ ថ្ងៃ) ក្នុងការដាក់អញ្ញត្រកម្មទាក់ទងទៅនឹងយុត្តាធិការបុគ្គល។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

សហមេធាវីការពារក្តីលោក អោ អាន

| | | |
|---|---|---|
| មុំ លុជ្ស | Richard ROGERS | Göran SLUITER |